# ទស្សនៈ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទខ្មែរចំពោះការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

web site: hoksavann.org

ថ្ងៃទី២៣ ឧសភា ២០០៦

ព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទ ជាពិសេសព្រះសង្ឃខ្មែរមានវិន័យតឹងជាងព្រះសង្ឃពុទ្ធសាសនាមហាយាន ។ ក្នុងបណ្តាព្រះសង្ឃថេរវាទទៀតសោត ព្រះសង្ឃខ្មែរមានវិន័យតឹងជាងព្រះសង្ឃថេរវាទដទៃទៀត ។ ព្រះសង្ឃពុទ្ធសាសនាថេរវាទរស់នៅបានដោយអាស្រ័យសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ ។ នៅសម័យពុទ្ធកាលក៏ដូចជាក្នុងព្រះវិន័យ មិនមានឃើញចែងថាព្រះសង្ឃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាដើមឡើយ ។ សូម្បីរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាមុនឆ្នាំ១៩៧០ ដែលចាត់ទុកព្រះសង្ឃជាពលរដ្ឋដូចពលរដ្ឋជាគ្រហស្ថដែរនោះ ក៏មិនឃើញតម្រូវឲ្យព្រះសង្ឃបោះឆ្នោតឡើយ ។ ចំណែកព្រះសង្ឃថេរវាទនៃប្រទេសដទៃទៀត ដូចជាព្រះសង្ឃប្រទេសថៃ ប្រទេសភូមាជាដើម ក៏មិនឃើញគេតម្រូវឲ្យបោះឆ្នោតដែរ រៀរលែងតែប្រទេសស្រីលង្កា ដែលក្នុងពេលថ្មីៗនេះ មិនត្រឹមតែអនុញ្ញាតឲ្យបោះឆ្នោតទេ ថែមទាំងព្រះសង្ឃបង្កើតជាគណបក្សនយោបាយថែមទៀត ។

កាលពីឆ្នាំ១៩៩៣ មានការបោះឆ្នោតអាណត្តិទី១ជ្រើសរើសតំណាងរាស្ត្រខ្មែរក្រោមកិច្ចចាត់ចែងរបស់អង្គការសហប្រជាជាតិ គេអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត ។ នៅឆ្នាំ១៩៩៨ ក៏អនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោតនៅក្នុងអាណត្តិទី២ លុះដល់អាណត្តិទី៣ឆ្នាំ២០០៣ ព្រះសង្ឃរាជគណៈមហានិកាយបានចេញសារាចរហាមមិនឲ្យព្រះសង្ឃបោះឆ្នោត ស្រាប់តែនៅឆ្នាំ២០០៦នេះ សម្តេចព្រះសង្ឃរាជគណៈមហានិកាយមានថេរដីកាថា នឹងចេញសារាចរបើកឲ្យព្រះសង្ឃបោះឆ្នោតវិញ សំរាប់ឆ្នាំ២០០៨ក្នុងអាណត្តិទី៤ ឯសារាចរដែលចេញមុនមិនឲ្យព្រះសង្ឃបោះឆ្នោតនោះទុកជាមោឃៈ ។ ម្តងបើកម្តងបិទម្តងបើកវិញនេះ គឺសម្តេចទេព-វង្សធ្វើតាមតែប្រមុខដឹកនាំរាជរដ្ឋាភិបាលនៃបក្សប្រជាជនប៉ុណ្ណោះ ។ បើមើលឃើញថាព្រះសង្ឃភាគ

ច្រើននឹងបោះឆ្នោតឲ្យបក្សប្រជាជនកម្ពុជា គេនឹងអនុញ្ញាតឲ្យព្រះសង្ឃបោះ បើពេលណាគេមើលឃើញថា ព្រះសង្ឃភាគច្រើននឹងមិនបោះឲ្យបក្សប្រជាជនទេ គេក៏បិទដោយនិយាយថាខុសវិន័យ ប៉ុន្តែពេលណាដែលគេអនុញ្ញាតព្រះសង្ឃបោះវិញនោះ គេពុំធ្លាប់និយាយថាខុសវិន័យឡើយ សូម្បីសម្ដេចទេព-វង្សធ្លាប់ធ្វើជាអនុប្រធាននៃរដ្ឋសភាសម័យរដ្ឋកម្ពុជា ក៏មិនដែលយកវិន័យមកនិយាយដែរ ។ សម្ដេចទេពវង្សជាបក្សជនពេញសិទ្ធិនៃគណបក្សប្រជាជនកម្ពុជា កាលនៅជាគ្រហស្ថមិនទាន់បួស ក៏ធ្លាប់ធ្វើជាអនុប្រធាននៃរណសិរ្សសាមគ្គីការពារនិងកសាងកម្ពុជាដែរ ។ ម្ល៉ោះហើយបានតែគ្រប់សកម្មភាពសំខាន់ៗរបស់សម្ដេចទេព-វង្ស តែងឈរលើគោលជំហរបក្សប្រជាជនកម្ពុជា ពុំឈរលើគោលជំហរព្រះពុទ្ធសាសនាឡើយ ។ គឺបើបក្សប្រជាជនមានបំណងយ៉ាងណាក្នុងបញ្ហាទាក់ទងនឹងព្រះពុទ្ធសាសនា សម្ដេចទេព-វង្សធ្វើតាមភ្លាម ឧទាហរណ៍ពីរក្នុងពេលថ្មីៗនេះ គឺទីមួយពេលដែលប្រមុខដឹកនាំរាជរដ្ឋាភិបាលនិយាយរិះគន់លោកកឹម-សុខា មិនចង់ឲ្យបើកវេទិកាសាធារណៈក្នុងវត្ត ភ្លាមនោះសម្ដេចទេព-វង្សចេញសារាចរហាមភ្លាម ដោយមិនបានប្រជុំសួរយោបល់មន្ត្រីសង្ឃដទៃទៀតឡើយ ទីពីរពេលដែលប្រមុខរាជរដ្ឋាភិបាលពោលចង់ឲ្យព្រះសង្ឃបោះឆ្នោត សម្ដេចទេព-វង្សក៏ធ្វើតាមភ្លាម ដោយមិនបានធ្វើមហាសន្និបាតវិសាមញ្ញសំរេចពីព្រះសង្ឃឡើយ ព្រោះបញ្ហានេះធំណាស់ បើសំរេចមិនត្រឹមត្រូវទេ ធ្វើឲ្យព្រះពុទ្ធសាសនាចុះតម្លៃខ្លួនឯងទៅវិញ ។ សម្ដេចទេព-វង្សសំរេចបានតែបញ្ហាផ្ទាល់ខ្លួន ប៉ុន្តែបញ្ហានេះជាបញ្ហាអាយុជីវិតព្រះពុទ្ធសាសនា ត្រូវតែសំរេចពីគណៈសង្ឃនិងពីពុទ្ធបរិស័ទខ្មែរ ព្រោះការបោះឆ្នោតនេះជាបញ្ហានយោបាយសុទ្ធសាធ ។

តាំងពីព្រះសង្ឃមានសិទ្ធិបោះឆ្នោតចាប់ពីសម័យអ៊ុនតាក់មក ព្រះសង្ឃត្រូវទទួលគ្រោះថ្នាក់ជាបន្តបន្ទាប់ ។ ព្រះសង្ឃណាគាំទ្រគណបក្សដទៃក្រៅពីគណបក្សកាន់អំណាច ព្រះសង្ឃនោះត្រូវគេធ្វើបាប ។ បានសេចក្ដីថា ព្រះសង្ឃអង្គណាមិនគាំទ្រគណបក្សប្រជាជន បែរជាគាំទ្រគណបក្សដទៃ ព្រះសង្ឃអង្គនោះត្រូវគេរុកគួន រហូតមិនអាចរស់នៅក្នុងវត្តបាន សូមលើកតែឧទាហរណ៍ពីរ គឺព្រះសង្ឃមួយអង្គនៅស្រុកមោង ខេត្តបាត់ដំបង ត្រូវគេដេញឲ្យសឹក ដោយចោទថាគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច, ព្រះសង្ឃមួយអង្គទៀត នៅវត្តឧណ្ណាលោមក្រុងភ្នំពេញបានរត់ចេញពីវត្តហើយសឹក ដោយការភិតភ័យពីការគំរាមកំហែង ដោយត្រូវគេចោទថា គាំទ្រគណបក្សសម-រង្ស៊ី ។ អ្នកដែលគំរាមកំហែងគឺព្រះសង្ឃនិងគណៈកម្មការវត្តដែលគាំទ្រគណបក្សប្រជាជន ។ គួរឲ្យភ័យរន្ធត់លើសពីនេះទៅទៀត គឺកាលពីឆ្នាំ១៩៩៨ មានព្រះសង្ឃជាច្រើនអង្គ បានត្រូវសុគតនិងរបួសដោយអំពើបង្ក្រាបហឹង្សារបស់អាជ្ញាធរខ្មែរ ទៅលើបាតុកម្មអហឹង្សារបស់ព្រះសង្ឃនិងពលរដ្ឋខ្មែររាប់ពាន់រាប់ម៉ឺននាក់ ដើម្បីឲ្យរាប់សន្លឹកឆ្នោតឡើងវិញ ។ ដូច្នេះបញ្ជាក់ថា បើកសិទ្ធិឲ្យព្រះ

សង្ឃបញ្ចេញមតិជ្រើសរើសតំណាងរាស្ត្រ និងសិទ្ធិធ្វើបាតុកម្ម ក៏មានចែងក្នុងរដ្ឋធម្មនុញ្ញ តែបែរជាគំរាមកំហែងចំពោះព្រះសង្ឃណាដែលមិនគាំទ្រគណបក្សប្រជាជន រហូតបាញ់ក្រុមបាតុករ ដែលធ្វើឲ្យព្រះសង្ឃនិងបាតុករដទៃទៀតត្រូវសុគតនិងស្លាប់អស់ជាច្រើន នេះជាប្រវត្តិសាស្ត្រដែលខ្មែរគ្រប់រូបបានចងចាំគ្រប់គ្នា ។

បំណាងគ្រប់គណបក្សនយោបាយចង់ឲ្យព្រះសង្ឃបោះឆ្នោត ព្រោះគណបក្សនីមួយៗយល់ថា ព្រះសង្ឃនឹងបោះឲ្យគណបក្សរបស់ខ្លួន ប៉ុន្តែគេមិនបានគិតឲ្យហ្មត់ចត់ថា បើឲ្យព្រះសង្ឃបោះឆ្នោតបែបនេះ តើនាំឲ្យព្រះពុទ្ធសាសនាមានផលវិបាកអាក្រក់បែបណាទេ គឺបំណាងទាញយកផលប្រយោជន៍ពីព្រះសង្ឃ តាមរយៈការពេះឆ្នោតតែប៉ុណ្ណោះ ។ គេចាត់ទុកព្រះសង្ឃមានសិទ្ធិស្មើគ្នា ដូចជាប្រជាពលរដ្ឋជាគ្រហស្ថ ប៉ុន្តែគេពុំបានគិតអំពីឋានៈនិងគុណធម៌ផ្សេងគ្នាទេ ។

ផ្នែកវិជ្ជមាន បើព្រះសង្ឃបោះឆ្នោត គេចាត់ទុកថាព្រះសង្ឃ បានបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋកម្ពុជា ក្នុងការចូលរួមក្នុងសង្គម ជាមួយពុទ្ធបរិស័ទជាគ្រហស្ថ ក្នុងកិច្ចបញ្ចេញមតិយោបល់ជ្រើសរើសអ្នកដឹកនាំរដ្ឋឲ្យបានល្អ ។ ផ្នែកអវិជ្ជមាន បើព្រះសង្ឃសំរេចបោះឆ្នោត ឈ្មោះថាព្រះសង្ឃបានប្រឡូកចូលធ្វើនយោបាយជាមួយគ្រហស្ថមួយផ្នែក ដែលធ្វើឲ្យគុណធម៌របស់ព្រះសង្ឃ ដែលធ្លាប់គេគោរព បានធ្លាក់ចុះមកក៏រឹតស្មើនឹងគ្រហស្ថ ។ ព្រះសង្ឃនិងព្រះសង្ឃបែកបាក់គ្នា ដោយសារគាំទ្រគណបក្សផ្សេងៗគ្នា ។ វត្តនិមួយៗត្រូវបែងចែក ដោយសារការគាំទ្រគណបក្សផ្សេងៗគ្នា គឺវត្តនេះរបស់គណបក្សឈ្មោះនេះ វត្តនោះរបស់គណបក្សឈ្មោះនោះ ។ ព្រះសង្ឃពុំមែនទស្សនៈផ្សេងគ្នា ដែលអាចក្លាយជាវិវាទរវាងព្រះសង្ឃគ្នាឯងទេ គឺអាចបង្កើតសត្រូវជាមួយគណបក្សណា ដែលមិនបានគាំទ្រថែមទៀត ។ ដូច្នេះព្រះសង្ឃអស់ភាពស្ថិតនៅកណ្តាល ដែលគ្រប់គណបក្សទាំងអស់ចូលមកគោរពបូជាហើយ ដោយសារការប្រកាន់គណបក្សរៀងៗខ្លួននេះឯង ។

តើគេអាចសង្ឃឹមថា ការបោះឆ្នោតអាណត្តិទី៤ឆ្នាំ២០០៨នេះ មិនដូចអាណត្តិមុនៗទេ អ្នកនយោបាយមានភាពចាស់ទុំហើយ ព្រះសង្ឃអាចបោះឆ្នោតបានដោយសេរីនិងយុត្តិធម៌ ទោះបីបោះឆ្នោតឲ្យគណបក្សណាមួយ តាមឆន្ទៈរបស់ខ្លួន គ្មានការគំរាមកំហែងដូចមុនទៀតទេ ។ នយោបាយមានភាពស្លាប់រស់ ពុំមែនធ្វើដោយការនឹកស្មានដូចយល់សប្តិឡើយ ។

ដើម្បីសក្ខីភាពសំរាប់ពិចារណាចំពោះបញ្ហានេះ សូមលើកយកឧទាហរណ៍ពីរបី ។ នៅប្រទេសឥណ្ឌា សតវត្សទី១៥ ព្រះពុទ្ធសាសនាបានត្រូវរលាយនៅក្នុងប្រទេសកំណើតរបស់ខ្លួន ក្រៅពីដោយសារសាសនាឥស្លាមមកបំផ្លាញព្រះពុទ្ធសាសនា មានដុតពុទ្ធិកសកលវិទ្យាល័យនាលន្ទាជាដើម ព្រះសង្ឃខ្លួនឯងក៏បានបន្ធូរបន្ថយវិន័យ ប្រព្រឹត្តធម៌តាមគ្រហស្ថ ដែលនន្ថែមទម្ងន់ឲ្យការវិនាសនោះ ឲ្យប្រព្រឹត្តទៅកាន់តែរហ័សថែមទៀត ។ ព្រះសង្ឃស្រីលង្កាដែលបង្កើតគណបក្សនយោបាយ

រហូតប្រណាំងប្រជែងឲ្យគេបោះឆ្នោត ដែលលទ្ធផលមានតំណាងរាស្ត្រ៦, ៧នាក់។ ពេលជជែកគ្នានៅក្នុងសភាជាតិ មានការប្រើសំដីវាយប្រហារគ្នា ប៉ះទង្គិចដល់ព្រះសង្ឃ រហូតប្រើហិង្សាតាមផ្លូវកាយទៀតផង ។ នៅកម្ពុជាក្រោម វៀតណាមបានបង្ខំឲ្យព្រះសង្ឃខ្មែរធ្វើស្រែ ឲ្យចិញ្ចឹមសត្វពាហនៈក៏ដូចជាគ្រហស្ថ គឺធ្វើតាមរបៀបព្រះសង្ឃពុទ្ធសាសនាមហាយាន ក្នុងបំណងបន្ថយតម្លៃព្រះពុទ្ធសាសនាថេរវាទ យូរទៅពុទ្ធបរិស័ទខ្មែរ នឹងឈប់គោរពបូជា ពុទ្ធសាសនានឹងរលាយ ព្រោះព្រះសង្ឃពុទ្ធសាសនាថេរវាទ រស់នៅដោយបច្ច័យ៤របស់ពុទ្ធបរិស័ទបូជា ដោយសារព្រះសង្ឃលះបង់អកុសលនិងកិច្ចកង្វល់មានកម្រិតខ្ពស់ ។

ដូចនេះ ព្រះសង្ឃដែលមានស្ថាប័នរបស់ខ្លួន ត្រូវតែស្ថិតនៅឯករាជ្យ កុំធ្វើតាមការអូសទាញរបស់អ្នកនយោបាយ ត្រូវរក្សាតម្លៃនិងផលប្រយោជន៍របស់ខ្លួន ។ បានសេចក្តីថា ត្រូវពង្រឹងព្រះពុទ្ធសាសនាឲ្យរឹងមាំនិងលូតលាស់ថែមទៀត ។ សំណើដែលទាក់ទងនឹងព្រះពុទ្ធសាសនារបស់រាជរដ្ឋាភិបាល ដូចជាសំណើរឲ្យព្រះសង្ឃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាដើម ត្រូវតែប្រជុំព្រះសង្ឃបញ្ញវ័ន្តពិចារណាឲ្យបានល្អិតល្អន់ តើការអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត នាំឲ្យខាតតម្លៃព្រះពុទ្ធសាសនាឬយ៉ាងណា ។ សូមកុំគិតថា ចង់ឲ្យព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរបោះឆ្នោត ព្រោះសាសនាដទៃនៅកម្ពុជាគេឲ្យអ្នកបួសគេបោះឆ្នោត ដើម្បីកុំឲ្យចាញ់ប្រៀបគេ ។ សូមក្រឡេកមើលឲ្យច្បាស់ អ្នកបួសគេគ្មានវិន័យតឹងរឹងទេ គេអាចធ្វើអ្វីបានដូចជារឿងនយោបាយ ធ្វើជំនួញជួញដូរគ្រប់យ៉ាងបាន គេរស់នៅដោយខ្លួនគេបាន ចំណែកអ្នកបួសពុទ្ធសាសនាថេរវាទខ្មែរវិញមានវិន័យតឹងរ៉ឹង ពុំអាចធ្វើការរកស៊ីដូចជាគ្រហស្ថបានទេ រស់នៅដោយសទ្ធាពុទ្ធបរិស័ទ បើធ្វើឲ្យខូចសទ្ធាពុទ្ធបរិស័ទ ព្រះសង្ឃប៉ុំអាចរស់នៅបានឡើយ ។ វិន័យនេះ ព្រះពុទ្ធបញ្ញត្តិហាមដោយការរិះគន់ពីពុទ្ធបរិស័ទ ។ ឥឡូវនេះ ព្រះពុទ្ធបដិនិញ្វនបាត់ទៅហើយ ពុំអាចទូលសួរព្រះអង្គថាតើអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត ឬពុំអនុញ្ញាត គឺហាមប្រាម ។ ដូច្នេះមានតែព្រះសង្ឃឈរលើជំហរខ្លួនឯង ដោយពិចារណាមើលឲ្យគ្រប់ជ្រុងជ្រោយ ស្របតាមកាលៈទេសៈ ដោយគិតពីផលប្រយោជន៍និងតម្លៃព្រះពុទ្ធសាសនាជាមូលដ្ឋាន ។

ល្អបំផុត ព្រះសង្ឃត្រូវស្ថិតនៅកណ្តាលរវាងគណបក្សទាំងអស់ ដោយយកគណបក្សទាំងអស់ជាមិត្ត ។ ធ្វើដូច្នេះអាចមានឥទ្ធិពលណែនាំគ្រប់គណបក្សទាំងអស់ ឲ្យស្ថិតនៅក្នុងធម៌សុចរិត ប្រកបដោយសាមគ្គីធម៌ ។ អាចណែនាំឲ្យបោះឆ្នោតប្រកបដោយសេរីនិងយុត្តិធម៌ ។ បើលំអៀងទៅម្ខាង អ្នកម្ខាងទៀតគេពុំស្តាប់ការណែនាំនោះទេ ។ ព្រះសង្ឃគួរតាំងខ្លួន ជាតំណាងយុត្តិធម៌ បើទៅប្រឡូកជាមួយគេ តំណាងយុត្តិធម៌នោះត្រូវបាត់បង់ ។គ្រប់គណបក្សទាំងអស់សុទ្ធតែជាពុទ្ធសាសនិកជន តែងតែគោរពព្រះសង្ឃ គួរតែពិចារណាអំពីបញ្ហាព្រះសង្ឃបោះឆ្នោតនេះ សំរេចនឹងអនុវត្តយ៉ាងណា កុំឲ្យតម្លៃស្ថាប័នព្រះពុទ្ធសាសនាជាតិ ដែលជាសាសនារប

ស់រដ្ឋ កុំធ្វើឲ្យព្រះពុទ្ធសាសនាសៅហ្មងឡើយ ។ តាមការសង្កេតមើលឃើញថា ប្រជាធិបតេយ្យ ដែលមានការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននៅកម្ពុជា នៅក្មេងខ្ចីណាស់ ពុំទាន់ចាស់ទុំនៅឡើយទេ ។ នៅប្រទេសដែលជឿនលឿនខាងលទ្ធិប្រជាធិបតេយ្យ គេឲ្យសិទ្ធិដល់ប្រជាពលរដ្ឋពេញបរិបូណ៌ ដូចការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនេះ ទោះប្រជាពលរដ្ឋណាបោះឲ្យគណបក្សណា គេចាត់ទុកថាជារឿងធម្មតា គេគ្មានរវល់យកចិត្តទុកដាក់តាមដានអ្នកបោះឆ្នោតឡើយ ។ ទោះបីមិនបោះឲ្យគេ ក៏គេនៅតែរាប់អានគ្នាដូចធម្មតា ។ នេះជាអនុសាសន៍សំរាប់ព្រះសង្ឃនិងគណបក្សនយោបាយ យកទៅពិចារណាមុននឹងសំរេចចំពោះបញ្ហាព្រះសង្ឃនិងការបោះឆ្នោតនេះ ដើម្បីរក្សាការពារព្រះពុទ្ធសាសនាឲ្យបានគង់វង់ ។៚

❑ ❑

❑